# ខ្ញុំបានឡើងភ្នំ FUJI (ហ្វីជិ) ដូចបំណងប្រាថ្នាហើយ ។



នៅថ្ងៃទី១២ ដល់ ទី១៤ ខែសីហា ក្នុងថ្ងៃឈប់សម្រាកថ្ងៃបុណ្យ(おぼんやすみ), ក្រុមហ៊ុន Takahashi Kensetsu និងក្រុមហ៊ុន Shintake Kougyou បានធ្វើដំណើររួមគ្នាឡើងភ្នំFuji ។ លោកប្រធាន Takahashi Isao នៃប្រធានក្រុមហ៊ុន Takahashi Kensetsu និងសមាជិកដ៏ទៃទៀត លោក Pham Quy Ngoc និងលោក Le Ngoc Cuong មកពីក្រុមហ៊ុន Takahashi Kensetsu, លោក Tran Xvan Hoa លោក Ho Pinh Hoang មកពីក្រុមហ៊ុន Shintake Kougyou និងសក្ខាកាមជាង៤នាក់ទៀត, ព្រមទាំងអ្នកធ្វើការនៅ ក្រុមហ៊ុន Shintake Kougyou ចំនួន៦នាក់ទៀត ។ រួមទាំងសក្ខាកាមផងដែរ, បើនិយាយពីភ្នំ Fuji សម្រាប់ជនជាតិជប៉ុន វាជាភ្នំមួយ ដ៏ពិសេស និងល្បីល្បាញណាស់ ។ មនុស្សគ្រប់គ្នាកំពុងតែទន្ទឹងរង់ចាំការឡើងភ្នំ Fuji ទោះពេលឡើងវាពិបាកមានចម្ងាយឆ្ងាយ ប៉ុន្តែវាធ្វើ ឲពួកគេសប្បាយរីករាយពេលបានឡើងទៅ ។ បន្ទាប់ពីបានគេងសម្រាកបន្តិចនៅក្នុងសណ្ឋាគារយើងបានចាប់ផ្តើមបន្តដំណើរឡើងទាំងយប់ងងឹត នៅឯនាយពេលកំពុងឡើងនៅតាមផ្លូវព្រះអាទិត្យចាប់ផ្តើមរះចេញពីពពក យើងបានឈប់បន្តិចដើម្បីមើលវា ។ លោកប្រធាន Takahashi គាត់បានឡើងភ្នំFuji ជាច្រើនដងមកហើយ វាមិនងាយស្រួលនោះទេ ។ តាមផ្លូវ, លោកប្រធានមានការព្រួយបារម្ភណ៍និងសក្ខាកាមទាំងអស់ហើយក៏ឲដើរឡើងរួមគ្នា លោកបាននិយាយថាគាត់ពិតជារីករាយខ្លាំងណាស់ ។



ការឡើងដល់កំពូលភ្នំហ្វីជិសាន់

ទោះជាសក្ខាកាមវ័យក្មេងក៏មានការពិបាកក្នុងការឡើងដែរ, ប៉ុន្តែលោក Ngoc បាននិយាយថា ″ ទោះជាលំបាកក្តី តែនៅពេលឡើង ដល់កំពូលភ្នំ វាពិតជាអស្ចារ្យខ្លាំងណាស់ជាមួយនឹងសោភ័ណ្ឌភាព ផ្ទៃមេឃនិងសមុទ្រពពកដ៏ស្រស់ស្អាត ″ ហើយវាជាអនុស្សាវរីយ៍មួយ ដែលគាត់និងចងចាំក្នុងមួយជីវិតគាត់ ។

លោក Takahashi គាត់បានរំលឹកពីការឡើងភ្នំពីមុនៗហើយនិយាយថា ″ ការរៀបចំគឺវាពិបាក ប៉ុន្តែអ្វីដែលទទួលបានគឺអស្ចារ្យណាស់, វាពិតជាសំខាន់ផងដែរក្នុងការមកលេងជាមួយគ្នាម្តងម្កាល ″ ។

## សក្ខាកាម៨នាក់បានប្រលងជាប់ភាសាជប៉ុន



នៅក្នុងការប្រឡងសមត្ថភាពភាសាជប៉ុនលើកដំបូងនៅឆ្នាំ ២០១៨ បានធ្វើឡើងនៅថ្ងៃទី ១ ខែកក្កដា (អាទិត្យ), សក្ខាកាម បច្ចេកទេសចំនួន ៥៧ នាក់ ធ្វើការនៅក្រុមហ៊ុនដែលជាសមាជិករបស់សហជីព បានធ្វើការប្រលង, ហើយ៨នាក់បានប្រលងជាប់ ។ កម្រិត N2 ពីរនាក់បានប្រឡងជាប់, ទឹកប្រាក់ចំនួន ៣ ម៉ឺនយ៉េនត្រូវបានផ្តល់ជូន ដោយបានបង្ហាញនៅចំពោះមុខ ។ ហើយតេស្តជំនាញភាសារជប៉ុនលើទី២, ប្រព្រឹត្តទៅនៅខែ កក្កដា និង ខែ ធ្នូ ។ ថ្ងៃប្រឡងបន្ទាប់គឺថ្ងៃទី២ ខែធ្នូ (អាទិត្យ) កម្មវិធីដាក់ពាក្យត្រូវបានបញ្ចប់រួចរាល់ ។ អ្នកដែលប្រឡង, ក្នុងអំឡុងពេលធ្វើការផងរៀនផងគឺវាមានការលំបាក ប៉ុន្តែមិនត្រូវបោះបង់ចោលនោះទេ សូមព្យាយាមឡើង ។

<បេក្ខជនដែលជោគជ័យ> ※ រាយនាម :

【N2】TONG VAN VUONG（㈱K-CRAFT）、និងម្នាក់ទៀតមិនស្គាល់ឈ្មោះ【N3】DOAN DAI LONG（㈲新紀創建）、HOANG MINH VUONG（㈲新紀創建）【N4】DINH TIEN SY（㈱NAO）、TRAN DINH DU（㈱フジダン）、NGUYEN VAN KIEM（㈲大和工業）【N5】HO DINH HOANG（㈲新建興業）

## ការមិនទទួលរងពីជំងឺគ្រុនផ្តាសាយធំ



ដើម្បីបង្ការជំងឺគ្រុនផ្តាសាយ, ត្រូវចាក់វ៉ាក់សាំងការពារបង្ការរោគ ត្រូវលាងដៃ・ខ្ពុល់មាត់・ពាក់ម៉ាស់ការពារមុខដែលមាន ប្រសិទ្ធិភាព ។ ការចាក់វ៉ាក់សាំងបង្ការរោគ វាមានតំម្លៃខុសគ្នាអាស្រ័យលើមន្ទីពេទ្យ ។ តំម្លៃចាក់វ៉ាក់សាំងការពារត្រូវស្វែងរកកន្លែងណា ដែលមានតំម្លៃសមរម្យដើម្បីចាក់ ។

## បទសម្ភាសន៍ជាមួយអ្នកប្រលងជាប់ភាសាជប៉ុន

【ឆ្នាំ២០១៨ ខែកក្កដា ប្រឡងជាប់ N2】
លោក TONG VAN VUONG（㈱K-CRAFT／រន្ទា）

### ខ្ញុំតែងតែរៀនជារៀងរាល់ថ្ងៃ



លោក VUONG នៅឆ្នាំ២០១៦ ខែធ្នូ បានមកប្រទេសជប៉ុនក្នុងនាមជាសក្ខាកាមហ្វឹកហាត់ជំនាញបច្ចេកទេស ។ ការប្រឡងកម្រិត N3 ឆ្នាំមុននៅខែកក្កដាបានប្រឡងជាប់, ហើយកម្រិត N2 លើកទី២ ក៏បានប្រឡងជាប់ផងដែរ ។ រៀងរាល់ថ្ងៃលោកមិនដែលខកខាន ក្នុងការរៀនភាសាជប៉ុនឡើយ ។ ចំពោះថ្ងៃធ្វើការ ត្រូវចំណាយពេលប្រហែលជា២ម៉ោង ទើបមកដល់បន្ទប់ស្នាក់នៅវិញ ។ ទោះជាម៉ោងសម្រាកពេលខ្លីឬពេលផ្លាស់ប្តូរកន្លែងធ្វើការ និងពេលទំនេរលោកតែងតែរៀន ដូចជារៀន អំពីពាក្យជាដើម ។ ចំពោះថ្ងៃឈប់សម្រាក គាត់រៀនប្រហែល៥ម៉ោងក្នុង១ថ្ងៃ ។ គាត់បានចំណាយពេលកន្លះឆ្នាំដើម្បីរៀនសម្រាប់ ការប្រឡងកម្រិត N2 ។ ឯកសារជំនួយរួមមាន: សៀវភៅ『新完全マスターシリーズ』និងសៀវភៅ（スリーエーネットワーク）គាត់បានរៀនសារចុះសារឡើង ៣ ទៅ ៤ ។ ហើយពាក្យនិងអក្សរកាន់ជិ ក្នុង១ថ្ងៃ ២០ ទៅ ៣០ បានមើលហើយមើលទៀត រហូតដល់តែចាំ ។ ដោយសារតែមិនមានពេលសម្រាប់អក្សរកាន់ជិ គាត់រៀនដោយមើលតែសៀវភៅរហូតដល់ចាំ ហើយគ្មានការសរសេរ ដោយដៃឡើយ ។ ចំពោះការស្តាប់សំនួរ មុនពេលស្តាប់ត្រូវយកចិត្តទុកដាក់ ហើយកំណត់នូវបញ្ហាអោយបានច្បាស់ ។ លោក VUONG គាត់និយាយថា ការរៀនវាមិនលំបាកនោះទេពីដំបូងឡើង ។ តែមនុស្សគ្រប់គ្នាគឺមិនអាចធ្វើតាមគាត់បាននោះទេ យ៉ាងណាក៏ដោយការសិក្សាតិចតួចជារៀងរាល់ថ្ងៃវាពិតជាសំខាន់ណាស់ ។



លោក VUONG (កណ្តាល), នៅក្បែរលោក NAM (ខាងឆ្វេង), លោក THONG (ខាងស្តាំ)